ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

<u>សំណុំរឿងព្រហ្មទណ្ឌលេខ</u> ៩៣

ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២

<u>សំណុំរឿងជម្រះលេខ</u> ៣២១

ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២

<u>សាលក្រមបណ្តឹងទាស់</u>

<u>លេខ</u> ២២ ឃ/២៣៣

ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣

# <u>តាងនាមប្រជារាស្ត្រខ្មែរ</u>

## <u>សាលាដំបូងខេត្តសៀមរាប</u>

ដែលបានបើកសវនាការជាសាធារណៈលើបណ្តឹងទាស់ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ នៅសាលាដំបូងខេត្តសៀមរាប

-បើកសវនាការថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១០:០០ នាទីព្រឹក

-ប្រកាសសាលក្រមនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១០:៤៥ នាទីព្រឹក។

ដោយមានសមាសភាពដូចខាងក្រោម៖

### <u>ចៅក្រមជំនុំជម្រះ</u>

លោក [redacted] ចៅក្រម និងជាអនុប្រធានសាលាដំបូងខេត្តសៀមរាប

### <u>តំណាងអយ្យការ</u>

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

### <u>ក្រឡាបញ្ជីសវនាការ</u>

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

<u>**ដើម្បីជំនុំជម្រះលើបណ្តឹងទាស់**</u> ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ របស់លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ណាក់** *ហៅ* [redacted] **ណាក់** ដែលបានប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ: ៤០(ខ)/៤១៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ: ៩៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២៖ [redacted] **ណាក់** *ហៅ* [redacted] **ណាក់** ភេទប្រុស កើតឆ្នាំ១៩៩១ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ[redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ន[redacted] ខេត្តសៀមរាប មុខរបរមិនពិតប្រាកដ ប្រពន្ធឈ្មោះ [redacted] **រ៉េត** ឪពុកឈ្មោះ [redacted] **ឡាន់** (ស្លាប់) ម្តាយឈ្មោះ [redacted] **រ៉េត** (រស់) ។

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] ណាក់ ហៅ [redacted] ណាក់ ។

ជនជាប់ចោទខាងលើនេះជាប់ចោទពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិផ្តុកស្នាច់ ឃុំគោកធ្លកលើ ស្រុកជីក្រែង ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែ

មករា ឆ្នាំ២០២២ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ និងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**រឿងហេតុ មានដូចតទៅ**

កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ១៦និង៣០នាទី ក្រោយពីទទួលបានព័ត៌មានពីប្រជាពលរដ្ឋពាក់ព័ន្ធនឹងករណីគ្រឿងញៀន កម្លាំងការិយាល័យប្រឆាំងគ្រឿងញៀន បានចុះប្រតិបត្តិការបង្ក្រាប និងឃាត់ខ្លួនបានឈ្មោះ [redacted] សុជា ហៅឡិក ដកហូតបានថ្នាំញៀន ចំនួន ១កញ្ចប់ ទម្ងន់ ១,១៨ (មួយក្បៀសដប់ប្រាំបី) ក្រាម នៅចំណុចភូមិថ្លុកស្នាច់ ឃុំគោកធ្លកលើ ស្រុកជីក្រែង ខេត្តសៀមរាប។ បន្ទាប់មកសមត្ថកិច្ចបានបន្តទៅឆែកឆេរនៅផ្ទះរបស់ឈ្មោះ[redacted]សុជា រកឃើញថ្នាំញៀនចំនួន ១កញ្ចប់ ទម្ងន់១,៧៥ (មួយក្បៀសចិតសិបប្រាំ) ក្រាម ជញ្ជីងសម្រាប់ថ្លឹងថ្នាំញៀនចំនួន១ ថង់សម្រាប់ច្រកថ្នាំញៀនមួយចំនួន និងឧបករណ៍ប្រើប្រាស់ថ្នាំញៀន មួយចំនួនទៀត។ ឈ្មោះ [redacted]សុជា បានឆ្លើយសារភាពថា ខ្លួនចេះប្រើប្រាស់ថ្នាំញៀនរយៈពេល ១ឆ្នាំហើយ ថ្នាំញៀនទិញពីឈ្មោះ [redacted] ណាក់។ នៅថ្ងៃកើតហេតុឈ្មោះ [redacted] ណាក់ បានទូរស័ព្ទមកខ្លួនដើម្បីឲ្យខ្លួនរំលែកថ្នាំញៀនដែលនៅសល់ចំនួន ១កញ្ចប់ ទៅជាចំនួន ២កញ្ចប់តូច ហើយប្រើខ្លួនយកថ្នាំញៀនទៅលក់ឲ្យគេក្នុងតម្លៃ ១០(ដប់) ដុល្លារអាមេរិក ពេលយកទៅលក់ឲ្យគេក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

តាមសាលក្រមព្រហ្មទណ្ឌលេខ ៤០(ខ)/៤១៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ដែលបានសម្រេចសេចក្តីដូចខាងក្រោម៖

**១/ផ្តន្ទាទោស:**

ក-ឈ្មោះ [redacted] សុជា ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូ[redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួនភូ[redacted] ខេត្តសៀមរាប មុខរបរកសិករ កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៨ ប្រពន្ធឈ្មោះ[redacted]ចិន្តា មានកូន ៣នាក់ ឪពុកឈ្មោះ [redacted] រីង (ស្លាប់) ម្តាយឈ្មោះ [redacted] អ៊ន់ (ស្លាប់) ទោសពីមុន គ្មាន។

ដាក់ពន្ធនាគារ កំណត់ ០៣ (បី) ឆ្នាំ តែទោសនេះ ត្រូវអនុវត្តដូចខាងក្រោម៖

-ទោសអនុវត្តក្នុងពន្ធនាគាររយៈពេល ០២ (ពីរ) ឆ្នាំ។

-ទោសនៅសល់ត្រូវព្យួរការអនុវត្តធម្មតាស្របតាមមាត្រា១០៤ ដល់មាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

ខ-ឈ្មោះ [redacted] ណាក់ ភេទប្រុស កើតឆ្នាំ១៩៨១ ជនជាតិខ្មែរ ទីកន្លែងកំណើត[redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្នភូ[redacted] ខេត្តសៀមរាប មុខរបរមិនពិតប្រាកដ ប្រពន្ធឈ្មោះ [redacted] រ៉េត ឪពុកឈ្មោះ [redacted] ឡាន់ (ស្លាប់) ម្តាយឈ្មោះ [redacted] រ៉េត (រស់) ។

ដាក់ពន្ធនាគារ កំណត់ ០៣ (បីរ) ឆ្នាំ។

ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិផ្អុកស្នាច់ ឃុំគោកធ្លកលើ ស្រុកជីក្រែង ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ និងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**<u>២/ចេញដីកាបង្គាប់ឱ្យចាប់ខ្លួន:</u>** ជនជាប់ចោទឈ្មោះ [redacted] ណាក់ យកមកឃុំខ្លួនក្នុងពន្ធនាគារតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**<u>៣/វត្ថុតាងរួមមាន:</u>**

-ថ្នាំញៀនប្រភេទ **មេតំហ្វេតាមីន** ចំនួន ២កញ្ចប់ ទម្ងន់២,៩៣ (ពីរក្បៀសកៅសិបបី) ក្រាម ត្រូវសម្រេចរឹបអូសបំផ្លាញចោល។

-**ជញ្ជីងថ្លឹងថ្នាំញៀន** ពណ៌ខ្មៅ ចំនួន១គ្រឿង និង**ទូរស័ព្ទដៃម៉ាក** NOKIA (ចុចពិល) ពណ៌ខ្មៅ ចំនួន១គ្រឿង ត្រូវសម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋ។

៤/សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុជា និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ណាក់។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

## <u>ពេលសវនាការ</u>

## <u>ក្រោយពីបាន</u>

-ពិនិត្យលើពាក្យបណ្តឹងទាស់ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ របស់លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ណាក់ ហៅ [redacted] ណាក់

-ស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] ណាក់ ហៅ ហៅ [redacted] ណាក់

-ស្តាប់អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សុជា

-ពិនិត្យលើរបាយការណ៍ស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌

-ស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] ណាក់ ហៅ [redacted] ណាក់

-ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ។

## <u>សំអាងហេតុ</u>

១-សាលាដំបូងខេត្តសៀមរាបជំនុំជម្រះ និងចេញសាលក្រមព្រហ្មទណ្ឌលេខ: ៥០ ខ/៤១៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ ជាសាលក្រមកំបាំងមុខជនជាប់ចោទឈ្មោះ លុយ ណាក់ ហៅ [redacted] ណាក់ ។ ជនជាប់ចោទឈ្មោះ [redacted] ណាក់ ហៅ [redacted] ណាក់ បានប្តឹងទាស់នឹងសាលក្រមខាងលើ ដោយជនជាប់ចោទស្នើសុំឱ្យតុលាការជំនុំជម្រះនៅចំពោះមុខឡើងវិញ។



Scanned with CamScanner

តាមការពិនិត្យឃើញថា ជនជាប់ចោទប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខខាងលើមាន លក្ខណៈត្រឹមត្រូវតាមមាត្រា៣៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលសាលាដំបូងខេត្តសៀមរាប អាចលើកយកមកជំនុំជម្រះសារជាថ្មីបានតាមមាត្រា៣៧១ និងមាត្រា៣៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ណាក់ ហៅ [redacted] ណាក់ បានឆ្លើយថា៖ រូបខ្លួនសុំបដិសេធចំពោះចម្លើយរបស់ឈ្មោះ [redacted] សុជា ដែលបានឆ្លើយថា បានទិញថ្នាំញៀនពីរូបខ្លួន។ ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] សុជា ឡើយ ចំពោះការចោទប្រកាន់ថា រូបខ្ញុំបាទបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន គឺខ្លួនសុំបដិសេធ ដោយហេតុថា ខ្លួនមិនធ្លាប់ប្រើប្រាស់គ្រឿងញៀន និងមិនស្គាល់ថ្នាំញៀនអ្វីនោះទេ។

៣-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សុជា បានឆ្លើយថា៖ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន។ សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ៣និង៣០នាទីរសៀល មូលហេតុដោយសារ ខ្លួនជាប់ពាក់ព័ន្ធនឹងករណីគ្រឿងញៀន។ ឈ្មោះ [redacted] ណាក់ ភេទប្រុស អាយុប្រហែល៣០ឆ្នាំ មានទីលំនៅភូមិត្រាចពក ឃុំគោកធ្លកលើ ស្រុកជីក្រែង ខេត្តសៀមរាប មានឪពុកឈ្មោះ [redacted](មិនស្គាល់ត្រកូល)(ស្លាប់) ម្តាយឈ្មោះ [redacted] (មិនស្គាល់ត្រកូល)(រស់) មានទីលំនៅភូមិស្វាយធំ ឃុំគោកធ្លកលើ ស្រុកជីក្រែង ខេត្តសៀមរាប ខ្លួនទើបតែស្គាល់រយៈពេល ៥ថ្ងៃមុនពេលកើតហេតុ។ ខ្លួនធ្លាប់ទិញថ្នាំញៀនពីឈ្មោះ [redacted] ណាក់ ជាច្រើនដង ជួនកាលទិញតម្លៃ ២០.០០០ (ពីរម៉ឺន)រៀល ជួនកាលទិញតម្លៃ ៣០.០០០ (បីម៉ឺន) រៀល និងជួនកាលទិញតម្លៃ ៥០.០០០ (ប្រាំម៉ឺន)រៀល ទិញយកមកប្រើប្រាស់ខ្លួនឯង។ នៅថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២២ ឈ្មោះ [redacted] ណាក់ បានទូរស័ព្ទមកខ្លួនឱ្យទៅយកថ្នាំញៀនប្រភេទ ម៉ាទឹកកកនៅខ្ទង់ទំនប់ដែលវាបានបង្កប់ចោល ពេលទៅដល់ឃើញថ្នាំញៀនចំនួន ៣កញ្ចប់ ដញ្ជើងថ្លឹងថ្នាំញៀនចំនួន១ និងថង់ក៏បសថ្លាមួយចំនួន។ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ ២០២២ ឈ្មោះ ឡាន់ ណាក់ បានទូរស័ព្ទឱ្យខ្លួនយកថ្នាំញៀនចំនួន ១កញ្ចប់ យកទៅលក់ឱ្យគេតែមិនបានប្រាក់ទេ។ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២២ ឈ្មោះ [redacted] ណាក់ បានទូរស័ព្ទមកខ្លួនម្តងទៀតថា ឱ្យខ្លួនយកថ្នាំញៀនចំនួន ១កញ្ចប់ ទៅលក់ឱ្យគេ ចំពោះប្រាក់គឺគេវេរទៅឱ្យឈ្មោះ [redacted] ណាក់ រួចហើយ។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ ឈ្មោះ [redacted] ណាក់ បានទូរស័ព្ទមកខ្លួនថា ឱ្យខ្លួនវែកថ្នាំញៀនដែលនៅសល់ចំនួន ១កញ្ចប់ ទៅជា២កញ្ចប់តូច ហើយឱ្យខ្លួនយកទៅឱ្យគេនៅតាមផ្លូវឆ្ងាយពីផ្ទះខ្លួនចម្ងាយ ៥០ម៉ែត្រ ខ្លួនក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ សមត្ថកិច្ចដកហូតថ្នាំញៀនចំនួន ២កញ្ចប់តូច ដញ្ជើងចំនួន១ ថង់ក៏បសថ្លាមួយចំនួន និងឧបករណ៍ប្រើប្រាស់មួយចំនួន។

៤-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន ស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទ ដោយហេតុថា កូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ គឺពុំមានភស្តុតាងណាមួយបញ្ជាក់ថា កូនក្តីខ្លួនបានប្រព្រឹត្តអំពើ ជួញដូរដោយខុស



Scanned with CamScanner

ច្បាប់នូវសារធាតុញៀន ក្រៅពីចម្លើយឆ្លើយដាក់របស់ជនជាប់ចោទឈ្មោះ [redacted] សុជា ទាំងដែលកូនក្តីខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] សុជា ឡើយ និងស្នើសុំបញ្ឈប់ដីបង្គាប់ឱ្យចាប់ខ្លួនលើកូនក្តីខ្លួន។

៥-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន ផ្លូងតាមការដេញដោលលើជនជាប់ចោទឈ្មោះ [redacted] ណាក់ ហៅ [redacted] ណាក់ ឃើញថា ពុំមានទំនាក់ទំនងរវាងជនជាប់ចោទឈ្មោះ [redacted] សុជា និងជនជាប់ចោទឈ្មោះ [redacted] ណាក់ ឡើយ ហេតុនេះ តំណាងអយ្យការស្នើសុំឱ្យតុលាការសម្រេចតាមនីតិវិធីលើឈ្មោះ [redacted] ណាក់។

៦-តាមលទ្ធផលនៃសវនាការលើអង្គសេចក្តីជាថ្មី ឃើញថាសាលក្រមព្រហ្មទណ្ឌលេខ ៤០ (ខ)/៤១៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ តុលាការយល់ឃើញថា តាមការពិនិត្យភស្តុតាង និងចម្លើយរបស់ឈ្មោះ [redacted] ណាក់ ឃើញថា ពុំមានភស្តុតាងណាមួយបញ្ជាក់ថា ឈ្មោះ [redacted] ណាក់ ហៅ [redacted] ណាក់ បានប្រព្រឹត្តអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ក្រៅពីចម្លើយរបស់ឈ្មោះ [redacted] សុជា ឆ្លើយដាក់នោះទេ។ ជាគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ គប្បីតុលាការសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] ណាក់ ហៅ [redacted] ណាក់ រួចផុតពីបទចោទ។

## សម្រេចសេចក្តី

១/ទទួលបណ្តឹងទាស់ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ របស់មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ណាក់ ហៅ [redacted] ណាក់ ទុកជាត្រឹមត្រូវតាមច្បាប់ ដែលសាលាដំបូងខេត្តសៀមរាប អាចលើកយកមកជំនុំជម្រះជាថ្មីម្តងទៀតតាមបញ្ញត្តិមាត្រា ៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២/តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ៤០ (ខ)/៤១៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ ទុកនៅដដែល ដោយគ្រាន់តែធ្វើកែប្រែដូចខាងក្រោម៖

ក.ឱ្យជនជនជាប់ចោទឈ្មោះ [redacted] ណាក់ ហៅ [redacted] ណាក់ ភេទប្រុស កើតឆ្នាំ១៩៩១ មានទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តសៀមរាប មុខរបរ មិនពិតប្រាកដ ប្រពន្ធឈ្មោះ [redacted] រ៉េត ឪពុកឈ្មោះ [redacted] ឡាន់ (ស្លាប់) ម្តាយឈ្មោះ [redacted] រ៉េត (រស់)។

រួចផុតពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិថ្នល់ស្នាច់ ឃុំគោកធ្លកលើ ស្រុកជីក្រែង ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តឱ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ.បញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួន៖ ជនជាប់ចោទឈ្មោះ [redacted] ណាក់ ហៅ [redacted] ណាក់។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ណាក់ ហៅ [redacted] ណាក់ ។



Scanned with CamScanner

ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា ហត្ថលេខា និងត្រា

[redacted] [redacted]

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

សៀមរាប, ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]